## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៣៤៣៣ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រា
## ចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការលើកលែង និងការអនុគ្រោះពន្ធប្រថាប់ត្រា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា
- បានឃើញប្រកាសលេខ ៥០៧ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា
- យោងតាមការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

### ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងធានាសង្គតិភាព នៃការប្រមូលពន្ធប្រថាប់ត្រា ចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ។

### ប្រការ ២.- គោលដៅ

ប្រកាសនេះមានគោលដៅកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រា ដែលត្រូវអនុវត្តចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ។

### ប្រការ ៣.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ដែលជាសំណង់ ឬ/និងដី ស្ថិតក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី និងខេត្ត នៃព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ៤.- និយមន័យនៃពាក្យសព្ទក្នុងឧបសម្ព័ន្ធ

សម្រាប់ឧបសម្ព័ន្ធនៃប្រកាសនេះ វាក្យសព្ទខាងក្រោម មានន័យដូចតទៅ÷

- **"តំបន់"** សំដៅដល់បណ្តុំនៃខណ្ឌពីរ ឬច្រើន នៃរាជធានីភ្នំពេញ ដែលរួមមានតំបន់ I និងតំបន់ II នៃរាជធានីភ្នំពេញ ដូចមានចែងក្នុងឧបសម្ព័ន្ធ
- **"ផ្លូវមេ"** សំដៅដល់ផ្លូវសំខាន់ៗទាំងឡាយដែលមានឈ្មោះ ឬលេខ ដូចមានចែងក្នុងឧបសម្ព័ន្ធ
- **"ផ្លូវរណប"** សំដៅដល់ផ្លូវទាំងឡាយដែលស្ថិតនៅស្របនឹងផ្លូវមេ និងភ្ជាប់ផ្លូវមេណាមួយ
- **"ច្រកផ្លូវ"** សំដៅដល់ផ្លូវទាំងឡាយដែលមានលក្ខណៈទ័ល ឬតូចចង្អៀតស្ថិតនៅចន្លោះផ្លូវមេ ឬចន្លោះផ្លូវរណប
- **"ផ្លូវឃុំ ឬផ្លូវសង្កាត់"** សំដៅដល់ផ្លូវទាំងឡាយដែលតភ្ជាប់ពីផ្លូវមេក្នុងតំបន់ II នៃរាជធានីភ្នំពេញ ឬផ្លូវទាំងឡាយដែលភ្ជាប់ពីផ្លូវមេក្នុងក្រុង ឬស្រុក នៃបណ្តាខេត្តនានា
- **"ផ្លូវភូមិ"** សំដៅដល់ផ្លូវទាំងឡាយដែលតភ្ជាប់ពីផ្លូវឃុំ ឬផ្លូវសង្កាត់ ឬបណ្តាញផ្លូវពីភូមិមួយទៅភូមិមួយ ក្នុងតំបន់ II នៅរាជធានីភ្នំពេញ ឬក្នុងក្រុង ឬស្រុក នៃបណ្តាខេត្តនានា។

**ប្រការ ៥.- មូលដ្ឋានគិតពន្ធប្រថាប់ត្រា**

អនុលោមតាមច្បាប់ជាធរមាន ពន្ធប្រថាប់ត្រាត្រូវបានកំណត់តាមអត្រា ៤% នៃតម្លៃអចលនទ្រព្យ ដែលជាកម្មវត្ថុនៃការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់។

មូលដ្ឋានគិតពន្ធប្រថាប់ត្រា ត្រូវបានកំណត់តាមលំដាប់អាទិភាព ដូចខាងក្រោម÷

១. តម្លៃអចលនទ្រព្យ ដែលត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

២. តម្លៃអចលនទ្រព្យ ដែលត្រូវបានកំណត់ក្នុងកិច្ចសន្យាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ ឬលិខិតគតិយុត្តពាក់ព័ន្ធផ្សេងទៀត ក្នុងករណីដែលមានតម្លៃស្មើ ឬខ្ពស់ជាងតម្លៃ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៦.- អវសានប្បញ្ញត្តិ**

ប្រកាសលេខ ៩៦២ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.- ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកឬអគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ តទៅ។

ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១៩

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ